**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

# សារលិខិត

## សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

## នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ក្នុងឱកាសប្រារព្ធទិវាអក្ខរកម្មជាតិ-អន្តរជាតិ ០៨ កញ្ញា ២០១៦

*-សូមក្រាបថ្វាយបង្គំសម្ដេចព្រះសង្ឃរាជទាំងពីរគណៈ ព្រះថេរានុថេរៈគ្រប់ព្រះអង្គជាទីសក្ការៈ*

*-សម្ដេច ឯកឧត្តម លោកជំទាវ ព្រឹទ្ធាចារ្យ លោកតា លោកយាយ អស់លោក លោកស្រី ជាទីមេត្រី*

*-លោកគ្រូ អ្នកគ្រូ ក្មួយៗសិស្សានុសិស្សជាទីស្រឡាញ់រាប់អាន និងជនរួមជាតិជាទីស្នេហា !*

ក្នុងឱកាសដ៏មហោឡារិកនៃ *ទិវាអក្ខរកម្មជាតិ-អន្តរជាតិ ០៨ កញ្ញា* នេះ ទូលបង្គំខ្ញុំព្រះករុណា ក្នុងនាមរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ខ្ញុំសូមសម្ដែងនូវសេចក្ដីសោមនស្សយ៉ាងក្រៃលែង និងសូមចូលរួមគាំទ្រយ៉ាងរីករាយជាមួយបងប្អូនជនរួមជាតិ អស់លោក លោកស្រី សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ បុគ្គលិកអប់រំ ព្រមទាំងក្មួយៗសិស្សានុសិស្សទាំងអស់ ចំពោះការរៀបចំប្រារព្ធទិវាដ៏មានសារៈសំខាន់ដែលជាមោទនភាពដ៏ខ្ពង់ខ្ពស់របស់កម្ពុជា ក្នុងទិសដៅកសាង និងអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាព និងគុណធម៌ រួមចំណែកកសាងសង្គមកម្ពុជាឱ្យកាន់តែរីកចម្រើនរុងរឿង។ ក្នុងស្មារតីនេះ ទូលព្រះបង្គំខ្ញុំព្រះករុណាខ្ញុំ សូមថ្លែងនូវសារលិខិតថ្វាយ និងប្រគេនព្រះថេរានុថេរៈគ្រប់ព្រះអង្គជាទីសក្ការៈ ជូនជនរួមជាតិ អស់លោក លោកស្រី សាស្ត្រាចារ្យ លោកគ្រូអ្នកគ្រូ បុគ្គលិកអប់រំ ព្រមទាំងក្មួយៗសិស្សានុសិស្សជាទីស្រឡាញ់ អំពីឆន្ទៈ និងបុព្វហេតុក្នុងការបន្តលើកកម្ពស់ការងារអក្ខរកម្ម និងជំរុញមនសិការរបស់បងប្អូនជនរួមជាតិយើងទាំងអស់រួមគ្នាលើកកម្ពស់ការងារនេះឲ្យកាន់តែល្អប្រសើរ ដើម្បីឧត្តមប្រយោជន៍របស់កម្ពុជាយើង និងមនុស្សជាតិទាំងមូល។ ឆ្នាំមុននេះ កម្ពុជាបានធ្វើយុទ្ធនាការអក្ខរកម្មជាតិពេញមួយឆ្នាំ ដោយទទួលបានលទ្ធផលល្អគួរជាទីមោទនៈ។ ប្រការនេះ បានបង្ហាញឲ្យឃើញពីការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាលកម្ពុជា និងការចូលរួមអនុវត្តយុទ្ធនាការអក្ខរកម្មជាតិរបស់ក្រសួងអប់រំ យុវជន និងកីឡា ក្រសួង និងស្ថាប័នពាក់ព័ន្ធ ព្រមទាំងអង្គការយូណេស្កូ និងដៃគូអភិវឌ្ឍនានា ជាពិសេសពីកិច្ចខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយចិត្តរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ មន្ត្រីរាជការ ព្រះសង្ឃ បញ្ញវន្ត សិស្សនិស្សិត និងក្រុមយុវជនស្ម័គ្រចិត្តនៅទូទាំងប្រទេស។

*ទិវាអក្ខរកម្មជាតិ-អន្តរជាតិ ០៨ កញ្ញា* ជាទិវាមួយមានអត្ថន័យឧត្តុង្គឧត្តមសម្រាប់ប្រទេសជាតិយើង ក៏ដូចជាពិភពលោកទាំងមូល ពីព្រោះអក្ខរកម្មជាគន្លឹះនៃការអភិវឌ្ឍន៍ រួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ហើយទិវានេះជាការរំឭកយើងថា យើងមានភារកិច្ចចម្បងចាំបាច់ច្រើនទៀត ដើម្បីជំរុញឲ្យមានអត្រាអក្ខរកម្មខ្ពស់ក្នុងចំណោមប្រជាជនកម្ពុជា ក៏ដូចជាទទួលបាននូវការ

សម្រេចគោលដៅអភិវឌ្ឍសហស្សវត្សរបស់ខ្លួនក្នុងឆ្នាំ ២០១៦-២០៣០ ដែលជាគោលដៅផ្តោតទៅលើបញ្ហាសំខាន់ៗដូចជា បញ្ហាសមធម៌ គុណភាព អប់រំ និងទស្សនទាននៃការរៀនសូត្រពេញមួយជីវិត។ ក្នុងស្មារតីនេះ រាជរដ្ឋាភិបាលតែងតែយកចិត្តទុកដាក់ខ្ពស់ ដោយប្រើប្រាស់សក្តានុពល សមត្ថភាព លទ្ធភាព និងកាលានុវត្តភាព ក្នុងការលើកកម្ពស់ការងារអក្ខរកម្មនេះ ពិសេសបង្កលក្ខណៈអំណោយផលល្អដល់ប្រជាពលរដ្ឋកម្ពុជា ឲ្យបានចូលរួមកាន់តែសកម្មខ្លាំងក្លាក្នុងការងារនេះ ដើម្បីបន្តដំណើរលើមាគ៌ាឆ្ពោះទៅកាន់វឌ្ឍនភាពដ៏រុងរឿងនៃសង្គមជាតិកម្ពុជាយើងទាំងមូល។

ការខិតខំប្រឹងប្រែងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ ក្នុងការធ្វើកំណែទម្រង់លើវិស័យអប់រំ យុវជន និងកីឡា បានធ្វើឲ្យវិស័យនេះមានការអភិវឌ្ឍ រីកចម្រើន និងមានមោទនភាព ស្របតាមកំណែទម្រង់របស់រាជរដ្ឋាភិបាល។ ឆ្នាំនេះទិវាអក្ខរកម្មជាតិ-អន្តរជាតិ ០៨ កញ្ញា ត្រូវបានប្រារព្ធឡើងក្រោមប្រធានបទ "អក្ខរកម្មជួយបង្កើនសេដ្ឋកិច្ចគ្រួសារ"។ ប្រធានបទនេះឆ្លុះបញ្ចាំងឲ្យឃើញថា អក្ខរជនដែលចេះជំនាញមុខរបរងាយៗ មានសមត្ថភាព ស្វែងយល់ និងវិភាគនូវព័ត៌មានសម្បូរបែប និងធ្វើឲ្យជីវិតកាន់តែប្រសើរជាងមុន តាមរយៈការបង្កបង្កើនផលការដាំដំណាំ បន្លែបង្ការ និងការចិញ្ចឹមសត្វ ព្រមទាំងចេះច្នៃបង្កើតនូវសម្ភារៈប្រើប្រាស់ក្នុងស្រុកថែមទៀតផង។ ប្រការនេះបង្ហាញថា អក្ខរកម្មមិនគ្រាន់តែធ្វើឲ្យអ្នកសិក្សា ចេះអាន ចេះសរសេរ ចេះនិយាយត្រឹមត្រូវនោះទេ ថែមទាំងធ្វើឲ្យចេះរកប្រាក់ចំណូលចិញ្ចឹមជីវិតខ្លួនឯងផង និងក្រុមគ្រួសារផង។

ជារួម យើងបានយល់ច្បាស់ណាស់ថា មានអក្ខរកម្មទើបមានចំណេះដឹង មានចំណេះធ្វើ និងមានការអភិវឌ្ឍ ពោលគឺអក្ខរកម្មផ្តល់នូវជំនាញមូលដ្ឋានដល់ប្រជាពលរដ្ឋគ្រប់រូប ក្នុងការប្រកបមុខរបរចិញ្ចឹមជីវិត ព្រមទាំងបន្តកែលម្អកម្រិតជីវភាពរស់នៅកាន់តែប្រសើរឡើង។ ម្យ៉ាងទៀត អក្ខរកម្មធ្វើឲ្យយើងចេះគិតពិចារណា និងសម្រេចចិត្តបានត្រឹមត្រូវ ពិសេសអក្ខរកម្មបង្កលក្ខណៈឲ្យអក្ខរជនបានយល់ដឹង និងស្វែងយល់នូវព័ត៌មានសម្បូរបែបទាំងក្នុង និងក្រៅប្រទេស ដើម្បីជាទុនក្នុងការត្រិះរិះពិចារណា និងរៀបចំដំណើរជីវិតរបស់ពួកគេទៅអនាគត។ ក្នុងន័យនេះ រាជរដ្ឋាភិបាលកម្ពុជានឹងបន្តប្តេជ្ញាចិត្តខ្ពស់ក្នុងការលើកកម្ពស់ការងារអក្ខរកម្ម និងជំរុញមនសិការរបស់បងប្អូនជនរួមជាតិយើងទាំងអស់ រួមគ្នាលើកកម្ពស់ការងារនេះ ឲ្យកាន់តែល្អប្រសើរ និងឈានទៅលុបបំបាត់អនក្ខរភាពរបស់ប្រជាជនយើងនៅពេលអនាគត។

ដោយឡែក ក្នុងឱកាសដ៏ល្អប្រពៃនេះ ទូលព្រះបង្គំខ្ញុំព្រះករុណាខ្ញុំ ក៏សូមថ្លែងអំណរគុណដល់គ្រប់ក្រសួង ស្ថាប័ន អង្គការជាតិ អន្តរជាតិ ដៃគូអភិវឌ្ឍ អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ សប្បុរសជននានា ព្រះសង្ឃ ចាស់ព្រឹទ្ធាចារ្យ បព្វជិតសាសនា និងប្រជាពលរដ្ឋទាំងអស់ ដែលបាន និងកំពុងជួយឧបត្ថម្ភគាំទ្រយ៉ាងសកម្ម ដល់ការងារអក្ខរកម្មនាពេលកន្លងមក។ ទូលព្រះបង្គំខ្ញុំព្រះករុណាខ្ញុំសង្ឃឹមថា ការប្រារព្ធទិវាអក្ខរកម្មជាតិ-អន្តរជាតិ ០៨ កញ្ញា នឹងបន្តដាស់ស្មារតីយើងទាំងអស់គ្នាឲ្យចូលរួមក្នុងការងារនេះកាន់តែសកម្មថែមទៀត។

*សម្តេច ព្រះថេរានុថេរៈគ្រប់ព្រះអង្គជាទីសក្ការៈ បងប្អូនជនរួមជាតិជាទីស្នេហា!*

ដើម្បីឈានទៅសម្រេចបានក្នុងគោលដៅអភិវឌ្ឍសហស្សវត្សដោយចីរភាព ឆ្នាំ២០៣០ និងដើម្បីផ្សារភ្ជាប់ការងារអក្ខរកម្មទៅនឹងការសិក្សាពេញមួយជីវិត ពិសេសឈានទៅសម្រេចបាននូវគោលដៅក្នុងបរិការណ៍ថ្មីគឺ ប្រែក្លាយពលករដែលប្រើកម្លាំងសុទ្ធសាធ ទៅជាការប្រើប្រាស់ជំនាញតាម "*យុទ្ធសាស្ត្រកំណើនថ្មី*" របស់កម្ពុជា ទូលព្រះបង្គំខ្ញុំព្រះករុណាខ្ញុំ សូមអំពាវនាវដល់ស្ថាប័នជាតិ អន្តរជាតិ

សហគមន៍ និងពលរដ្ឋគ្រប់រូប សូមយកចិត្តទុកដាក់ខ្ពស់ជាបន្តទៀត ដល់ការងារអក្ខរកម្ម ក៏ដូចជាការងារអប់រំទាំងនៅក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ។

ក្នុងស្មារតីនេះ ដើម្បីបន្តចូលរួមលើកកម្ពស់ការងារអក្ខរកម្មនៅកម្ពុជាឲ្យកាន់តែមានប្រសិទ្ធភាពថែមទៀត ទូលព្រះបង្គំខ្ញុំព្រះករុណាខ្ញុំ សូមអំពាវនាវដូចតទៅ ៖

ទី១-សមាជិក សមាជិកាពជរដ្ឋាភិបាល និងមន្ត្រីពជការគ្រប់លំដាប់ថ្នាក់ ពេលចុះបំពេញការងារតាមមូលដ្ឋានត្រូវឆ្លៀតចុះឲ្យដល់ថ្នាក់អក្ខរកម្ម មជ្ឈមណ្ឌលសិក្សាសហគមន៍ ដើម្បីលើកទឹកចិត្ត និងរួមចំណែកដោះស្រាយរាល់សំណូមពររៀនសូត្រតាមភាពជាក់ស្តែង។

ទី២-អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ត្រូវយកចិត្តទុកដាក់ចូលរួមគាំទ្រឲ្យបានខ្លាំងក្លាបន្ថែមទៀតក្នុងការជំរុញណែនាំប្រជាពលរដ្ឋដែលមិនបានរៀនសូត្រ ឬបោះបង់ការសិក្សា ឲ្យមានឱកាសទទួលបានការរៀនសូត្រជាថ្មី តាមថ្នាក់រៀនអប់រំក្រៅប្រព័ន្ធតាមគ្រប់រូបភាព ពិសេសត្រូវខិតខំបង្កលក្ខណៈងាយស្រួលដល់ប្រជាពលរដ្ឋដែលជាជនពិការ ឲ្យទទួលបានលទ្ធភាពក្នុងការសិក្សារៀនសូត្រ។

ទី៣-មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ លោកគ្រូ អ្នកគ្រូ ត្រូវបង្កើនឆន្ទៈ និងពង្រឹងក្រមសីលធម៌វិជ្ជាជីវៈជាគ្រូបង្រៀន ដើម្បីចូលរួមលើកកម្ពស់ការងារអប់រំទាំងក្នុង និងក្រៅប្រព័ន្ធឲ្យមានការអភិវឌ្ឍឈានឡើង ទាំងផ្នែកបរិមាណ និងគុណភាព ហើយត្រូវសកម្មផុសផុលចូលរួមក្នុងការងារកំណែទម្រង់វិស័យអប់រំ។ ក្នុងស្មារតីនេះ ខ្ញុំនៅតែចង់គូសបញ្ជាក់ម្តងហើយម្តងទៀតថា "ការកែទម្រង់គឺរស់ មិនកែទម្រង់គឺស្លាប់"។

ទី៤-ប្រព័ន្ធផ្សព្វផ្សាយទាំងអស់រួមមាន វិទ្យុ ទូរទស្សន៍ សារព័ត៌មាន ទស្សនាវដ្ដី ព្រឹត្តិបត្រព័ត៌មានរបស់រដ្ឋ និងឯកជន សូមជួយផ្សព្វផ្សាយឲ្យបានទូលំទូលាយអំពីអានុភាពនៃការងារអក្ខរកម្មដល់ប្រជាពលរដ្ឋយើង ដើម្បីឲ្យមានការយល់ដឹងកាន់តែទូលំទូលាយពោលគឺ "អក្ខរកម្មជួយបង្កើនសេដ្ឋកិច្ចគ្រួសារ"។

ទី៥-ក្មួយៗជាសិស្ស និស្សិត តាមគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន ក្រុមយុវជនសហភាពសហព័ន្ធយុវជនកម្ពុជា ក្រុមយុវជនកាយឫទ្ធិ និងក្រុមយុវជនកាកបាទក្រហមកម្ពុជា ត្រូវសកម្មចូលរួមជួយបង្រៀនដោយស្ម័គ្រចិត្តដល់អ្នកមិនចេះអក្សរនៅតាមថ្នាក់អក្ខរកម្ម និងមជ្ឈមណ្ឌលសិក្សាសហគមន៍ ដែលស្ថិតក្នុងមូលដ្ឋានរបស់ក្មួយៗរស់នៅ។ ចំណែកបងប្អូនជនរួមជាតិដែលជាមាតាបិតា ឬអ្នកអាណាព្យាបាល ក៏សូមជួយជំរុញបងប្អូនកូនចៅឲ្យបានចូលរៀនតាមសាលារៀនចំណោះទូទៅគ្រប់ៗគ្នា។ ដោយឡែក ក្មួយៗ និងបងប្អូនដែលពុំទាន់ចេះអក្សរ ឬបោះបង់ការសិក្សា ចូរខិតខំប្រឹងប្រែងរៀនសូត្រនៅតាមថ្នាក់អក្ខរកម្មថ្នាក់សមមូល និងមជ្ឈមណ្ឌលសិក្សាសហគមន៍ ដែលនៅជិតភូមិឋានរបស់ខ្លួន។

ទី៦-វត្តអារាម និងវិហារសាសនានានា ត្រូវចលនាព្រះសង្ឃ បព្វជិតសាសនា តាជី ដូនជី ចូលរួមជំរុញកម្មវិធីអក្ខរកម្មវិជ្ជាជីវៈឲ្យកាន់តែខ្លាំងក្លាថែមទៀត តាមរយៈការទេសនាអប់រំអំពីសារប្រយោជន៍នៃការរៀនសូត្រ។

ទី៧-ដៃគូអភិវឌ្ឍ ពិសេសអង្គការមិនមែនរដ្ឋាភិបាល ត្រូវបង្កើនកិច្ចសហការ និងពង្រឹងភាពជាដៃគូ ដោយជួយឧបត្ថម្ភគាំទ្រដល់កម្មវិធីអប់រំក្រៅប្រព័ន្ធ ពិសេសកម្មវិធីអក្ខរកម្មផ្សារភ្ជាប់នឹងការអប់រំវិជ្ជាជីវៈឲ្យមានដំណើរការល្អជាប់ជាប្រចាំ។

ទី៨-ប្រធានរោងចក្រ សហគ្រាស និងក្រុមហ៊ុនឯកជន សូមជួយជំរុញបើកថ្នាក់អក្ខរកម្មគួបផ្សំជាមួយថ្នាក់បំប៉នមុខជំនាញវិជ្ជាជីវៈផ្សេងៗ ដល់បងប្អូនកម្មករ កម្មការិនី ដើម្បីជាប្រយោជន៍របស់ពួកគេផង និងជាប្រយោជន៍ម្ចាស់រោងចក្រសហគ្រាសផង ដោយយើងទាំងអស់គ្នាត្រូវចងចាំថា "មានអក្ខរកម្ម មានការគិតគូរ និងការសម្រេចចិត្តបានត្រឹមត្រូវ" "មានអក្ខរកម្ម នាំឲ្យសេដ្ឋកិច្ចជាតិកាន់តែរីកចម្រើន" "មានអក្ខរកម្ម នាំឲ្យសង្គមជាតិកាន់តែអភិវឌ្ឍ និងមានភាពសុខដុម"។

ក្នុងស្មារតីនៃការខិតខំប្រឹងប្រែងអនុវត្តការងារទាំងអស់នេះ ទូលព្រះបង្គំខ្ញុំព្រះករុណាខ្ញុំសង្ឃឹមយ៉ាងមុតមាំថា សង្គមជាតិរបស់យើងកាន់តែទទួលបាននូវអត្រាកំណើនអក្ខរកម្ម ព្រមទាំងបន្តលើកកម្ពស់ចំណេះដឹង ជំនាញវិជ្ជាជីវៈ ការអភិវឌ្ឍសមត្ថភាព ជីវភាពរស់នៅក្នុងគ្រួសារឲ្យប្រកបដោយភាពរឹងមាំ មានសេចក្តីថ្លៃថ្នូរ ហើយសង្គម-សេដ្ឋកិច្ចជាតិទាំងមូល កាន់តែមានការអភិវឌ្ឍផងដែរ។ ទូលព្រះបង្គំខ្ញុំព្រះករុណាខ្ញុំ មានជំនឿ និងក្តីសង្ឃឹមយ៉ាងមុតមាំចំពោះ សម្តេច ឯកឧត្តម លោកជំទាវ បងប្អូនជនរួមជាតិ អស់លោក លោកស្រី សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ បុគ្គលិកអប់រំ នឹងចូលរួមយ៉ាងសកម្មទាំងអស់គ្នាលើការងារអក្ខរកម្មនេះ។ ទូលព្រះបង្គំខ្ញុំព្រះករុណាខ្ញុំ សូមឧទ្ទិសទិវាអក្ខរកម្មជាតិ-អន្តរជាតិ ០៨ កញ្ញា ២០១៦ ក្រោមប្រធានបទ "អក្ខរកម្មជួយបង្កើនសេដ្ឋកិច្ចគ្រួសារ" ឲ្យពង្រឹងបានបន្ថែមទៀតនូវឆន្ទៈប្តូរផ្តាច់របស់ប្រជាពលរដ្ឋកម្ពុជាយើង និងការយកចិត្តទុកដាក់ខ្ពស់ជាប្រចាំ លើការងារអក្ខរកម្មនៅទូទាំងព្រះរាជាណាចក្រកម្ពុជាយើង។

ជាទីបញ្ចប់ ទូលព្រះបង្គំជាខ្ញុំព្រះករុណាខ្ញុំ សូមថ្វាយព្រះពរ និងប្រគេនពរ សម្តេចព្រះសង្ឃរាជ ព្រះថេរានុថេរៈគ្រប់ព្រះអង្គ និងជូនពរបងប្អូនជនរួមជាតិ អស់លោក លោកស្រី សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ បុគ្គលិកអប់រំ ព្រមទាំងក្មួយៗជាទីស្រឡាញ់ទាំងអស់ សូមសមប្រកបដោយពុទ្ធពរបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១៦

ហ៊ុន សែន